ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៥ រថ.នក.សដណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

ក្រសួងរ៉ែ និងថាមពល មានកិត្តិយសសូមជូនដំណឹងដល់អ្នកនាំចេញផលិតផលរ៉ែ ឬបុគ្គលមានបំណងស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ ឱ្យបានជ្រាបថា ដើម្បីពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងរ៉ែ និងថាមពល បានដាក់ឱ្យអនុវត្ត**សេចក្តីណែនាំស្តីពីនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ ក្នុងទម្រង់អេឡិចត្រូនិកនៃប្រព័ន្ធបញ្ជរតែមួយជាតិ**។

សេចក្តីដូចបានជម្រាបជូនខាងលើ និងអនុលោមតាមបញ្ញត្តិនៃប្រកាសលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ អ្នកនាំចេញផលិតផលរ៉ែ ឬបុគ្គលស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ អាចដាក់ពាក្យស្នើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ ឬលិខិតបញ្ជាក់សំណាករ៉ែ ស្របតាមខ្លឹមសារនៃសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលខាងលើក្នុងទម្រង់អេឡិចត្រូនិក (Online) តាមរយៈតំណភ្ជាប់ https://live.nsw.gov.kh ឬចូលទៅកាន់គេហទំព័រផ្ទាល់របស់ប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកនាំចេញផលិតផលរ៉ែ ឬបុគ្គលស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ ជាពិសេសធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

រដ្ឋមន្ត្រី

កែវ រតនៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០០០៦...រ៉ែ.នគ.សលាន

ថ្ងៃ ចន្ទ ១០កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ

អនុលោមតាមបញ្ញត្តិនៃប្រកាសលេខ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ ក្រសួងរ៉ែ និងថាមពល កំណត់នូវនីតិវិធីនៃកិច្ចដំណើរការក្នុងការផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម។ នីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ រួមមាន (I) នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ និង (II) ការប្រើប្រាស់លិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ។

### I. នីតិវិធីនៃកិច្ចដំណើរការស្នើសុំនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ

ការផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

**១. ការចុះឈ្មោះក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ** (Trader)

អ្នកនាំចេញផលិតផលរ៉ែ ដែលទទួលបានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល អាចស្នើសុំគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ ឬបុគ្គលមានបំណងស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ ត្រូវបំពេញបែបបទដូចខាងក្រោម៖

- ចុះឈ្មោះសុំបង្កើតគណនីចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈគេហទំព័រ www.nsw.gov.kh ដោយភ្ជាប់នូវឯកសារពាក់ព័ន្ធ មានជាអាទិ៍៖
    - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប)



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- ○ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព
- ○ ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក។

- ក្រោយពីបានចុះឈ្មោះរួចហើយ ម្ចាស់គណនីត្រូវចូលប្រើប្រាស់ប្រព័ន្ធ តាមរយៈកូដសម្ងាត់ ដែលទទួលបានពីប្រព័ន្ធ និងត្រូវរក្សាទុកឱ្យមានសុវត្ថិភាព ដើម្បីប្រើប្រាស់ប្រកបដោយស្មារតីទទួលខុសត្រូវ។

## ២. ការនាំចេញផលិតផលរ៉ែ

### ២.១. ការស្នើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ

អ្នកនាំចេញផលិតផលរ៉ែ ដែលមានបំណងស្នើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ ត្រូវបំពេញបែបបទដូចខាងក្រោម៖

- បន្ទាប់ពីទទួលបានគណនីចូលប្រើប្រាស់ប្រព័ន្ធដូចបានកំណត់នៅក្នុងចំណុចទី១ ខាងលើ អ្នកនាំចេញផលិតផលរ៉ែ ត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ និងភ្ជាប់នូវឯកសារគាំទ្រនានា ក្នុងទម្រង់អេឡិចត្រូនិក តាមរយៈគេហទំព័រ www.nsw.gov.kh
- ផ្ទៀងផ្ទាត់ឡើងវិញនូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវនូវរាល់ទិន្នន័យដែលបានបំពេញរួច មុននឹង (Submit) ដាក់ស្នើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ
- តាមដានព័ត៌មាននៃការឆ្លើយតប ការស្នើសុំកែតម្រូវ និង/ឬភ្ជាប់ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិកបន្ថែម តាមការតម្រូវរបស់មន្ត្រីជំនាញនៃក្រសួងរ៉ែ និងថាមពល ដែលមានសមត្ថកិច្ច។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានធនធានរ៉ែ អាចតម្រូវឱ្យអ្នកនាំចេញផលិត-ផលរ៉ែដាក់ឯកសារគាំទ្រនានាជាឯកសាររឹង (Hard Copy) ជូនក្រសួងរ៉ែ និងថាមពល

ក្នុងករណីប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ អ្នកនាំចេញផលិតផលរ៉ែ អាច៖

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល
- យកលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ ដែលចេញដោយក្រសួងរ៉ែ និងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែជាឯកសាររឹង (Hard Copy)។

### ២.២. ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ

អ្នកនាំចេញផលិតផលរ៉ែ ដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ ត្រូវបំពេញបែបបទដូចខាងក្រោម៖

- បន្ទាប់ពីទទួលបានលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ (Code) ដូចបានកំណត់នៅក្នុងចំណុចទី២.១ ខាងលើ អ្នកនាំចេញផលិតផលរ៉ែ ត្រូវបំពេញ

ទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ និងភ្ជាប់នូវឯកសារគាំទ្រនានា ក្នុងទម្រង់អេឡិចត្រូនិក តាមរយៈគេហទំព័រ www.nsw.gov.kh

- ផ្ទៀងផ្ទាត់ឡើងវិញនូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវនូវរាល់ទិន្នន័យដែលបានបំពេញរួច មុននឹង (Submit) ដាក់ស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ
- តាមដានព័ត៌មាននៃការឆ្លើយតប ការស្នើសុំកែតម្រូវ និង/ឬភ្ជាប់ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិកបន្ថែម តាមការតម្រូវរបស់មន្ត្រីជំនាញនៃក្រសួងរ៉ែ និងថាមពល ដែលមានសមត្ថកិច្ច។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានធនធានរ៉ែ អាចតម្រូវឱ្យអ្នកនាំចេញផលិតផលរ៉ែដាក់ឯកសារគាំទ្រនានាជាឯកសាររឹង (Hard Copy) ជូនក្រសួងរ៉ែ និងថាមពល

ក្នុងករណីប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ អ្នកនាំចេញផលិតផលរ៉ែ អាច៖

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល
- យកវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ ដែលចេញដោយក្រសួងរ៉ែ និងថាមពល ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែជាឯកសាររឹង (Hard Copy)។

## ៣. ការនាំចេញសំណាករ៉ែ (លិខិតបញ្ជាក់សំណាករ៉ែ)

បុគ្គលដែលមានបំណងស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ ត្រូវបំពេញបែបបទដូចខាងក្រោម៖

- ត្រូវស្នើសុំនាយកដ្ឋានជំនាញចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សំណាករ៉ែឱ្យបានត្រឹមត្រូវ មុននឹងស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ
- បន្ទាប់ពីទទួលបានការពិនិត្យផ្ទៀងផ្ទាត់នូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវពីនាយកដ្ឋានជំនាញ បុគ្គលអាចចូលប្រើប្រាស់គណនីក្នុងប្រព័ន្ធដូចបានកំណត់នៅក្នុងចំណុចទី១ ខាងលើ និងត្រូវបំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ និងភ្ជាប់នូវឯកសារគាំទ្រនានា ក្នុងទម្រង់អេឡិចត្រូនិក តាមរយៈគេហទំព័រ www.nsw.gov.kh
- ផ្ទៀងផ្ទាត់ឡើងវិញនូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវនូវរាល់ទិន្នន័យដែលបានបំពេញរួច មុននឹង (Submit) ដាក់ស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ
- តាមដានព័ត៌មាននៃការឆ្លើយតប ការស្នើសុំកែតម្រូវ និង/ឬភ្ជាប់ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិកបន្ថែម តាមការតម្រូវរបស់មន្ត្រីជំនាញនៃក្រសួងរ៉ែ និងថាមពល ដែលមានសមត្ថកិច្ច។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានធនធានរ៉ែ អាចតម្រូវឱ្យបុគ្គលដាក់ឯកសារគាំទ្រនានាជាឯកសាររឹង (Hard Copy) ជូនក្រសួងរ៉ែ និងថាមពល

ក្នុងករណីប្រព័ន្ធដំណើរការពុំទាន់បានរលូនឬពេញលេញ បុគ្គល អាច៖

- យកឯកសាររឹង (Hard Copy) មកដាក់ស្នើសុំនៅក្រសួងរ៉ែ និងថាមពល

- យកលិខិតបញ្ជាក់សំណាករ៉ែ ដែលចេញដោយក្រសួងរ៉ែ និងថាមពល ជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិជំហានដំបូង និង
- ស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីបោះពុម្ពលិខិតបញ្ជាក់សំណាករ៉ែជាឯកសាររឹង (Hard Copy)។

## ៤. ការផ្ទៀងផ្ទាត់សំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ (Verifier)

នាយកដ្ឋានជំនាញ ដែលពាក់ព័ន្ធនឹងការផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

- ពិនិត្យនិងផ្ទៀងផ្ទាត់ភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃទិន្នន័យដែលបានបំពេញក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធបញ្ជរតែមួយជាតិ និងឯកសារគាំទ្រនានាដែលបានភ្ជាប់ក្នុងទម្រង់អេឡិចត្រូនិក
- ពិនិត្យភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃផលិតផលរ៉ែ និងសំណាករ៉ែដែលជាកម្មវត្ថុនៃការស្នើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ស្នើឱ្យអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ កែតម្រូវបំពេញបន្ថែម និង/ឬផ្តល់ឯកសារគាំទ្រនានាបន្ថែមក្នុងទម្រង់អេឡិកត្រូនិក។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានធនធានរ៉ែ អាចអញ្ជើញអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ មកធ្វើការបំភ្លឺ ឬផ្តល់ព័ត៌មានដោយផ្ទាល់
- បដិសេធសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ ក្នុងករណីរកឃើញមានភាពមិនត្រឹមត្រូវមិនអាចកែតម្រូវ ឬបំពេញបន្ថែមបាន និង/ឬមិនស្ថិតក្នុងកម្មវត្ថុនៃការផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ និង
- បោះពុម្ពលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែជាឯកសាររឹង (Hard Copy) ក្នុងករណីមានការស្នើសុំរបស់អ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ ក្រោយពីមានការសម្រេចពីថ្នាក់ដឹកនាំនៃក្រសួងរ៉ែ និងថាមពល។

## ៥.ការទូទាត់បង់ប្រាក់លើសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ (Cashier)

ការិយាល័យគ្រប់គ្រងចំណូលមិនមែនសារពើពន្ធធនធានរ៉ែ របស់នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ នៃអគ្គនាយកដ្ឋានធនធានរ៉ែ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ករណីអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ បង់សាច់ប្រាក់ផ្ទាល់ មន្ត្រីត្រូវ៖
  - ○ សរសេរបង្កាន់ដៃទទួលប្រាក់ពីអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ និង
  - ○ បំពេញលេខរៀងដើម្បីកំណត់សម្គាល់ក្នុងប្រព័ន្ធ រួចចុចពាក្យ បានបង់ប្រាក់រួច។
- ករណីអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ បង់ប្រាក់តាមប្រព័ន្ធធនាគារ មន្ត្រីត្រូវ៖
  - ○ ពិនិត្យព័ត៌មានក្នុងបណ្ណបង់ប្រាក់ដែលអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ បានបញ្ចូលក្នុងប្រព័ន្ធ និង
  - ○ បំពេញលេខរៀងដើម្បីកំណត់សម្គាល់ក្នុងប្រព័ន្ធ រួចចុចពាក្យ បានបង់ប្រាក់រួច។

**៦. ការត្រួតពិនិត្យឡើងវិញលើសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ (Reviewer)**

ថ្នាក់ដឹកនាំដែលជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ ដែលទទួលបានការឯកភាព និងបញ្ជូនមកពីនាយកដ្ឋានជំនាញពាក់ព័ន្ធ និង
- បញ្ជូនត្រឡប់ទៅតាមរចនាសម្ព័ន្ធក្នុងប្រព័ន្ធបញ្ជរតែមួយជាតិដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ក្នុងករណីរកឃើញមានភាពមិនប្រក្រតី។

**៧. ការសម្រេចសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិត-ផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ (Approver)**

ថ្នាក់ដឹកនាំនៃក្រសួងរ៉ែ និងថាមពល មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

- ពិនិត្យ និងសម្រេចលើការផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ តាមសំណើរបស់អ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ
- បញ្ជូនត្រឡប់ទៅអគ្គនាយកដ្ឋានធនធានរ៉ែ ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ ក្នុងករណីរកឃើញចំណុចខ្វះខាតដែលត្រូវបំពេញបន្ថែម និង
- បដិសេធសំណើសុំផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែវិញ្ញាបន-បត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ។

**រំហូរ និងថិរវេលានៃនីតិវិធីនៃកិច្ចដំណើរការក្នុងការអនុញ្ញាតឱ្យនាំចេញ ផលិតផលរ៉ែនិងសំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ ជាឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំនេះ។**

II. **ការប្រើប្រាស់លិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ**

អ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ ត្រូវបញ្ចូលទិន្នន័យលេខលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ និងទិន្នន័យចាំបាច់ផ្សេងទៀត នាពេលបំពេញប្រតិវេទន៍គយក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ។

ទទួលបានសេចក្តីណែនាំនេះ សូម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋានជំនាញ មន្ត្រីជំនាញពាក់ព័ន្ធ និងអ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ ត្រូវអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ នេះតទៅ។

រដ្ឋមន្ត្រី

កែវ_រតនៈ

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានធនធានរ៉ែ
  "ដើម្បីសហការផ្សព្វផ្សាយ"
- គ្រប់នាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានធនធានរ៉ែ
  និងអង្គភាពពាក់ព័ន្ធ "ដើម្បីអនុវត្ត"
- អ្នកនាំចេញផលិតផលរ៉ែ ឬសំណាករ៉ែ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ០០០៣ រ៉ែ.នក.ណណ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

## ក. រំហូរនីតិវិធីការងារ នៃការស្នើសុំលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ



ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ ០០០៦ រ៉ែ.នក.សណ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

## ខ.រំហូរនីតិវិធីការងារ នៃការស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ



ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ ០០០៦ អ៥ស.សណណ ចុះថ្ងៃទី....១៩....ខែ....កុម្ភៈ....ឆ្នាំ២០២៤

## គ.រំហូរនីតិវិធីការងារ នៃការស្នើសុំលិខិតបញ្ជាក់សំណាករ៉ែ



ឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំលេខ០០០៦ រ៉ែ.សក.ណឈ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

# ចិរវេលា នៃរំហូរនីតិវិធីការងារ

## ស្នើសុំលិខិតផ្តល់គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែ

## វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែ និងលិខិតបញ្ជាក់សំណាករ៉ែ តាមប្រព័ន្ធបញ្ជរតែមួយជាតិ

(រយៈពេលនៃថ្ងៃធ្វើការ)

| ល.រ | អ្នកនាំចេញ | មន្ត្រីពិនិត្យ | | | | មន្ត្រីបេឡា | ក្រុមហ៊ុន | មន្ត្រីបេឡា | ថ្នាក់ដឹកនាំពិនិត្យឡើងវិញ | | | | ថ្នាក់ដឹកនាំពិនិត្យអនុម័ត | សរុបចិរវេលានៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | (៣ថ្ងៃ) | | | | (កន្លះថ្ងៃ) | (មិនកំណត់) | (កន្លះថ្ងៃ) | (១ថ្ងៃ) | | | | (កន្លះថ្ងៃ) | (៥ថ្ងៃកន្លះ) |
| ១ | កូតានាំចេញ រ៉ែឧស្សាហកម្ម ថ្មអារ និងខ្សាច់ | ការិយាល័យជំនាញ | នាយកដ្ឋានជំនាញ | អគ្គនាយករងទទួលបន្ទុក | ប្រព័ន្ធជូនដំណឹងទៅក្រុមហ៊ុនឱ្យមកទទួលលិខិតបញ្ជាបង់ប្រាក់ | ចេញលិខិតបញ្ជាបង់ប្រាក់ព្រីនចេញពីប្រព័ន្ធ NRMIS | ក្រោយពីទទួលលិខិតបញ្ជាបង់ប្រាក់ក្រុមហ៊ុនត្រូវទៅបង់ប្រាក់នៅធនាគារ និងបញ្ចូលបណ្ណបង់ប្រាក់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ | ក្រោយពីនិត្យឃើញថាក្រុមហ៊ុនបានបញ្ចូលបណ្ណបង់ប្រាក់ទៅក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ មន្ត្រីបេឡាត្រូវអនុម័តបញ្ជូនឯកសារបន្ត | អគ្គនាយក | អនុរដ្ឋលេខាធិការ | រដ្ឋលេខាធិការទទួលបន្ទុក | រដ្ឋលេខាធិការទទួលបន្ទុកចង្កោម | រដ្ឋមន្ត្រី | |
| | | (១ថ្ងៃ) | | | | (កន្លះថ្ងៃ) | (មិនកំណត់) | (កន្លះថ្ងៃ) | (១ថ្ងៃ) | | | | | (៣ថ្ងៃ) |
| ២ | វិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែឧស្សាហកម្ម ថ្មអារ និងខ្សាច់ | ការិយាល័យជំនាញ | នាយកដ្ឋានជំនាញ | អគ្គនាយករងទទួលបន្ទុក | ប្រព័ន្ធជូនដំណឹងទៅក្រុមហ៊ុនឱ្យមកទទួល | ចេញលិខិតបញ្ជាបង់ប្រាក់ព្រីនចេញពីប្រព័ន្ធ NRMIS | ក្រោយពីទទួលលិខិតបញ្ជាបង់ប្រាក់ក្រុមហ៊ុនត្រូវទៅបង់ប្រាក់នៅធនាគារ និង | ក្រោយពីនិត្យឃើញថាក្រុមហ៊ុនបានបញ្ចូលបណ្ណបង់ប្រាក់ទៅក្នុងប្រព័ន្ធបញ្ជរតែ | អគ្គនាយក | អនុរដ្ឋលេខាធិការ | | | រដ្ឋលេខាធិការទទួលបន្ទុក ឬ រដ្ឋមន្ត្រី | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | លិខិតបញ្ជាបង់ប្រាក់ | | បញ្ចូលបណ្ណបង់ប្រាក់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ | មួយជាតិ មន្ត្រីបេឡាត្រូវអនុម័តបញ្ជូនឯកសារបន្ត | | | | | | |
| | | (១ថ្ងៃ) | | | | (កន្លះថ្ងៃ) | (មិនកំណត់) | (កន្លះថ្ងៃ) | (១ថ្ងៃ) | | | | (កន្លះថ្ងៃ) | (៣ថ្ងៃកន្លះ) |
| ៣ | **លិខិតបញ្ជាក់សំណាករ៉ែ** | ការិយាល័យជំនាញ | នាយកដ្ឋានជំនាញ | អគ្គនាយករងទទួលបន្ទុក | ប្រព័ន្ធជូនដំណឹងទៅក្រុមហ៊ុនឱ្យមកទទួលលិខិតបញ្ជាបង់ប្រាក់ | ចេញលិខិតបញ្ជាបង់ប្រាក់ព្រីនចេញពីប្រព័ន្ធ NRMIS | ក្រោយពីទទួលលិខិតបញ្ជាបង់ប្រាក់ក្រុមហ៊ុនត្រូវទៅបង់ប្រាក់នៅធនាគារ និងបញ្ចូលបណ្ណបង់ប្រាក់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ | ក្រោយពីនិត្យឃើញថាក្រុមហ៊ុនបានបញ្ចូលបណ្ណបង់ប្រាក់ទៅក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ មន្ត្រីបេឡាត្រូវអនុម័តបញ្ជូនឯកសារបន្ត | អគ្គនាយក | អនុរដ្ឋលេខាធិការ | រដ្ឋលេខាធិការទទួលបន្ទុក | រដ្ឋលេខាធិការទទួលបន្ទុកចង្កោម | រដ្ឋមន្ត្រី | |